## សិក្ខាសាលា

## ភាពជាដៃគូលើវិស័យព្រៃឈើ និងជលផលនៅកម្ពុជា៖

## បទពិសោធន៍ មេរៀន និងនវានុវត្តន៍នានា រយៈពេល១០ឆ្នាំ កន្លងមក

**ថ្ងៃពុធ ៥កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧**

**ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣**

**សណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ**

### ១. សេចក្តីផ្តើម

គម្រោងភាពជាដៃគូលើវិស័យព្រៃឈើ និងជលផលនៅកម្ពុជា ហៅកាត់ PaFF ចែកជា៣ដំណាក់កាល ចាប់ពី ខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែមិថុនា ឆ្នាំ២០២៣ ត្រូវបានចូលរួមអនុវត្តដោយ អង្គការរីខូហ្វ (RECOFTC) អង្គការ Non-Timber Forest Products Exchange Programme (NTFP-EP) អង្គការ World Wildlife Fund for Nature (WWF) និង អង្គការ Culture and Environment Preservation Association (CEPA)។

PaFF ទទួលថវិកាពីទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការស្វីស (SDC) និងទីភ្នាក់ងារស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ (Sida)។ ក្នុងការអនុវត្តសកម្មភាពគម្រោងកន្លងមក គម្រោងក៏ទទួលបានការគាំទ្រថវិកាពីដៃគូអភិវឌ្ឍនានាផងដែរ។

ក្នុងការអនុវត្តការងាររបស់ខ្លួនគម្រោង បានសហការយ៉ាងជិតស្និទជាមួយ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន ខ័ណ្ឌរដ្ឋបាលព្រៃឈើ និងខ័ណ្ឌរដ្ឋបាលជលផល នៃមន្ទីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន មន្ទីទេសចរណ៍ អាជ្ញាធរដែនដីទាំងថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ នៅតាមខេត្ត ដែលជាគោលដៅរបស់គម្រោង (កំពង់ធំ ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង)។

PaFF បានគាំទ្រដល់សហគមន៍គ្រប់គ្រងធនធានធម្មជាតិ ចំនួន១៥៥ (សហគមន៍ព្រៃឈើចំនួន១២០ សហគមន៍នេសាទ ចំនួន២៤ និងសហគមន៍តំបន់ការពារធម្មជាតិចំនួន ១១) ដែលមានសមាជិក ៣០១៧២ គ្រួសារ។ ក្នុងរយៈពេល១០ឆ្នាំកន្លងមក PaFF បានជួយគាំទ្រដល់ការរៀបចំ និងអនុវត្តន៍ផែនការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ ផ្តួចផ្តើម និងអនុវត្តន៍យន្តការហិរញ្ញប្បទានដើម្បីឲ្យ សហគមន៍គោលដៅទាំងនេះមានលទ្ធផលអនុវត្តផែនការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេ និងរួមចំណែកលើកកំពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍។ ជាងនេះទៀតគម្រោង PaFF បានជួយកសាងបណ្តាញសហគមន៍ (សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ) ដើម្បីឲ្យពួកគេមានសមត្ថភាពចូលរួមវេទិកានានាជាមួយអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទាំងនេះបានរួមចំណែកលើកកំពស់ប្រសិទ្ធភាពការគ្រប់គ្រងសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ ស្របតាមបទដ្ឋានគតិយុទ្ធនានាក្នុងវិស័យព្រៃឈើ និងជលផល នៅប្រទេសកម្ពុជា។ ក្នុងន័យនេះការចែករំលែកបទពិសោធន៍ និងឆ្លុះបញ្ចាំងពីមេរៀននានាដែលទទួល បានពីការអនុវត្តគម្រោងរយៈពេល១០ឆ្នាំកន្លងមក ជាមួយអ្នកពាក់ព័ន្ធនានាក្នុងវិស័យព្រៃឈើ និងវិស័យជលផលពិតជាមានសារ

សំខាន់ណាស់។ សិក្ខាសាលាស្តីពី **ភាពជាដៃគូលើវិស័យព្រៃឈើ និងជលផលនៅកម្ពុជា ៖ បទពិសោធន៍ មេរៀន និងនវានុវត្តន៍នានា រយៈពេល១០ឆ្នាំ កន្លងមក** និងរៀបចំឡើងនៅ ថ្ងៃពុធ ៥កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២៣ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។

## ២. គោលបំណង

គោលបំណងសំខាន់នៃសិក្ខាសាលានេះគឺដើម្បីចែករំលែកលទ្ធផលគម្រោង PaFF ទទួលបានពីការអនុវត្តការងារគម្រោង ក្នុងរយៈពេល១០ឆ្នាំកន្លងមក ផ្តល់វេទិកាឆ្លុះបញ្ចាំងពី ភាពប្រឈម និងនវានុវត្តន៍ ដែលគម្រោងទទួលបាន។ ជាងនេះទៀតសិក្ខាសាលានេះផ្តល់ឱកាសឲ្យការពិភាក្សា និងរៀនសូត្រពីបទពិសោធន៍នៃភាពជាដៃគូសម្រាប់គាំទ្រដល់សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងប្រទេសកម្ពុជា។

## ៣. សមាសភាពអ្នកចូលរួម

សិក្ខាសាលានេះនឹងមានអ្នកចូលរួម ចំនួន១២០រូប អញ្ជើញមកពីស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន មន្ទីរទេសចរណ៍ អាជ្ញាធរមូលដ្ឋាន ដៃគូរអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ វិស័យឯកជន ស្ថាប័នសិក្សា សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ។

## ៤. កម្មវិធីសិក្ខាសាលា (សេចក្តីព្រាង)

| ម៉ោង | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ – ០៨:៤៥ | ការអញ្ជើញមកដល់ និងចុះឈ្មោះសិក្ខាកាម | ក្រុមការងារគម្រោង |
| ០៨:៤៥ – ០៩:៣០ | **មតិស្វាគមន៍ និងកម្មវិធីបើក៖**<br>- មតិស្វាគមន៍របស់**តំណាង**ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការប្រទេសស្វីស (SDC)<br>- មតិស្វាគមន៍របស់**តំណាង**រដ្ឋបាលជលផល<br>- មតិបើកសិក្ខាសាលារបស់**តំណាងរដ្ឋបាលព្រៃឈើ** | ក្រុមការងារគម្រោង |
| ០៩:៣០ – ០៩:៤៥ | សម្រាកអាហារសម្រន់ | |
| ០៩:៤៥ – ១០:៣០ | **បទបង្ហាញអំពីលទ្ធផល និងបទពិសោធន៍របស់គម្រោង PaFF**<br>សំនួរ និងចម្លើយ | ក្រុមការងារគម្រោង |
| ១០:៣០ – ១២:០០ | **យន្តការហិរញ្ញប្បទានដោយសហគមន៍ ៖** ឥណទានសហគមន៍ និងមូលនិធិអាណត្តិព្យាបាលភាព | ក្រុមការងារគម្រោង |
| | **អំពីការចូលរួមរបស់សហគមន៍ក្នុងការអនុវត្តច្បាប់ក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ៖** សកម្មភាពល្បាតសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ | ក្រុមការងារគម្រោង |
| ១២:០០ – ១៣:៣០ | សម្រាកពិសារអាហារថ្ងៃត្រង់ | |

| | | |
|---|---|---|
| ១៣:៣០ – ១៥:០០ | **ការអភិវឌ្ឍ សហគមន៍ព្រៃឈើ សហគំន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ ៖** ការលើកំពស់ជីភាពសមាជិកសហគមន៍ និងការការពារធនធានធម្មជាតិក្នុងសហគមន៍ (កសិរុក្ខកម្ម សហគ្រាសសហគមន៍ ការរៀបចំព្រៃលំហែកម្សាន្ត) | ក្រុមការងារគម្រោង |
| | **បណ្តាញសហគមន៍ គ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ (CBNRM) ៖** យន្តការចែករំលែកព័តមាន ពង្រឹងសមត្ថភាពសមាជិសហគមន៍ និងបរិយាប័ន្នក្នុងការកាគ្រប់គ្រង សហគមន៍ព្រៃឈើ សហគំន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ | ក្រុមការងារគម្រោង |
| ១៥:០០ – ១៥:១៥ | អាហារសម្រន់ | ក្រុមការងារគម្រោង |
| ១៥:១៥ – ១៦:១៥ | ការឆ្លុះបញ្ចាំងពីភាពជាដៃគូសម្រាប់គាំទ្រដល់សហគមន៍ ក្នុងវិស័យព្រៃឈើ និងវិស័យជលផលនៅកម្ពុជា | ក្រុមការងារគម្រោង |
| ១៦:១៥ – ១៧:០០ | **បូកសរុបលទ្ធផល និងកម្មវិធីបិទ៖**<br>- មតិចំណាប់អារម្មណ៍របស់តំណាងអង្គការវីខូហ្វ<br>- មតិចំណាប់អារម្មណ៍របស់តំណាងទីភ្នាក់ងារស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (Sida)<br>- មតិបិទសិក្ខាសាលារបស់តំណាងក្រសួងបរិស្ថាន | ក្រុមការងារគម្រោង |

*ចំណាំ៖ អ្នករៀបចំសូមរក្សាសិទ្ធក្នុងការកែប្រែក្នុងករណីចាំបាច់។*